*បណ្ណាល័យសាធារណៈរ៉ូឆេស្ទ័រសូមស្វាគមន៍លោកអ្នក*

*យើងខ្ញុំរីករាយបំរើជូនលោកអ្នក និងសង្ឃឹមថាលោកអ្នកនឹងទទួលបានផលប្រយោជន៍*

*ពីអ្វីៗគ្រប់យ៉ាងដែលបណ្ណាល័យផ្តល់ជូន ។*
**សេវាបកប្រែ ( តាមទូរស័ព្ទ)**

**គេប់ភាសាទាំងអស់អាចរកបាននៅតាមតផល់សេវាសាធារណៈណាមយក៏បាននៅកង បណាល័យ ។.**

បណ្ណាល័យទទួលបានការឧបត្ថម្ភពីប្រាក់ពន្ធក្នុងស្រុក។ ប្រសិនបើលោកអ្នករស់នៅជុំវិញ ឬនៅតំបន់រ៉ូឆេស្ទ័រ ផ្ទាល់ លោកអ្នកបានរួមវិភាគទានជួយដល់បណ្ណាល័យតាមរយៈប្រាក់ពន្ធរបស់លោកអ្នក ។ចំពោះអ្នកដែលមិនរស់នៅក្នុងតំបន់រ៉ូឆេស្ទ័រទេ ឬអ្នកដែលគ្មានប័ណ្ណសមាជិកបណ្ណាល័យសាធារណៈរដ្ឋមីនីសូតាណាមួយផ្សេងទៀតទេ លោកអ្នក នឹងត្រូវស្នើអោយបង់វិភាគទានចូលបណ្ណាល័យតាមរយៈការបង់ប្រាក់កំរៃជាភ្ញៀវ ។

ដើម្បីប្រើអ៊ិនធឺណិត ឬមើលឯកសារសំភារៈបណ្ណាល័យនៅក្នុងបណ្ណាល័យសាធារណៈរ៉ូឆេស្ទ័រ ឬបណ្ណាល័យចល័ត លោកអ្នកត្រូវចុះបញ្ជីយកប័ណ្ណសមាជិកបណ្ណាល័យ ។ បុគ្គលិកបណ្ណាល័យនឹងជួយលោកអ្នក ក្នុងដំណើរការចុះបញ្ជីទទួលប័ណ្ណសមាជិកបណ្ណាល័យរបស់លោកអ្នកផ្ទាល់ ។ ការកាន់កាប់ប័ណ្ណសមាជិកបណ្ណាល័យគឺជាឯកសិទ្ធិនិងការទទួលខុសត្រូវមួយ ។ សូមយកប័ណ្ណសមាជិកបណ្ណាល័យតាមខ្លួន នៅពេលណាដែលអ្នកចង់ប្រើប្រាស់អ៊ិនធឺណិត ឬរកមើលឯកសារ ក្នុងបណ្ណាល័យ ។ សូមរក្សាការពារប័ណ្ណនេះទុកដូចជាអត្តសញ្ញាណប័ណ្ណផ្ទាល់ខ្លួន ឬប័ណ្ណឥណទាន (Credit Card)។ សូមកុំអោយអ្នកដទៃខ្ចីប័ណ្ណសមាជិកបណ្ណាល័យរបស់អ្នក ។ អ្នកនឹងទទួលខុសត្រូវសងសំភារៈទាំងអស់ ដែលកត់ត្រាចេញពីបណ្ណាល័យនៅក្នុងប័ណ្ណរបស់អ្នកនាកាលបរិច្ឆេទដែលដល់កំនត់ត្រូវសងវិញ ។ ប្រសិនបើសំភារៈណាមួយត្រូវសងវិញយឺតពេល អ្នកនឹងត្រូវបង់ប្រាក់ថ្លៃពេលវេលាលើសកំនត់នោះ ។ ក្នុងករណីសំភារៈដែលបានខ្ចីមិនត្រូវបានសងមកបណ្ណាល័យវិញ អ្នកនឹងត្រូវសងថ្លៃដាក់ជំនួសសំភារៈថ្មី ។

ការកត់ត្រារបស់បណ្ណាល័យដែលភ្ជាប់ឈ្មោះអ្នកប្រើប្រាស់បណ្ណាល័យទៅនឹងសំភារៈឬប្រធានបទជាក់លាក់ ត្រូវចាត់ថ្នាក់ឯកជនដោយច្បាប់រដ្ឋមីនីសូតា ។

ប្រសិនបើអ្នកមានចម្ងល់ទាក់ទងនឹងប័ណ្ណរបស់អ្នក ឬប្រសិនបើអ្នកត្រូវការជំនួយក្នុងការប្រើប្រាស់បណ្ណាល័យ សូមសួររកជំនួយពីបុគ្គលិកប្រចាំការនៅតាមតុនានា ។

Rochester Public Library

101 2nd Street SE — 507-285-8000

www.rochesterpubliclibrary.org

**អ៊ិនធឺណិត និងកុំព្យូទ័រវាយអត្ថបទ អាចរកបាន។**

## ការប្រមូលផ្តុំជាភាសាខ្មែរ (កម្ពុជា)៖

វីដេអូ និងសៀវភៅមនុស្សចាស់ជាភាសាខ្មែរស្ថិតនៅទីតាំងតំបន់ភាសាបរទេស (ក្បែរទស្សនាវដ្តី) នៅជាន់ទី២នៃបណ្ណាល័យ។ សៀវភៅមាននិយាយអំពីប្រវត្តិសាស្ត្រ ភាសា និងវប្បធម៌ខ្មែរ។ ការប្រមូលផ្តុំវីដេអូរួមមានរឿងកំប្លែង រឿងល្ខោន និងភ្លេង។

ផ្នែកកុមារនៅជាន់ទី១ ក៏មានសំភារៈជាភាសាខ្មែរមានជាអាទិ៖ សៀវភៅ វីដេអូ និងកាសែ្សតសំលេង។ បើចង់ស្តាប់រឿងរបស់កុមារជាភាសាខ្មែរ សូមចុចលេខ ២៨៧-២៦០៥ ហើយបន្ទាប់មកចុចលេខ ៤។ អាចរកបាន ២៤ម៉ោងក្នុងមួយថ្ងៃ។

## ការប្រមូលផ្តុំផ្នែកអក្សរសាស្ត្រ៖

បណ្ណាល័យមានកាសែ្សតសំលេង កាសែ្សតវីដេអូ កម្មវិធីកុំព្យូទ័រ និងសៀវភៅសំរាប់អ្នកដែលចង់រៀនភាសាអង់គ្លេស ឬបង្កើនជំនាញភាសាអង់គ្លេសរបស់គេ។ សំភារៈបណ្ណាល័យភាគច្រើនស្ថិតនៅជាន់ទី២នៃបណ្ណាល័យ ដោយមានលេខ ទូរស័ព្ទ ៤២៨។ ឯកសារអក្សរសាស្ត្រខ្លះសរសេរជាពីរភាសាគឺ អង់គ្លេស-ខ្មែរ ស្ថិតនៅក្នុងចំណោមការប្រមូលផ្តុំជាភាសា **ខ្មែរ** (កម្ពុជា)។